ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល

វិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ......024......សកបយ.

ភ្នំពេញ ថ្ងៃទី 13 ខែ តុលា ឆ្នាំ ១៩៩៩

# សារាចរ
## ស្តីពី
## ប្រាក់ឈ្នួល នៃការងារពេលយប់

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបលោក លោកស្រីជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងដែនអនុវត្ត នៃច្បាប់ស្តីពីការងារ ឲ្យបានជ្រាបថា ផ្អែកតាមការកំណត់ នៃច្បាប់ស្តីពីការងារ កម្មករ និយោជិត ដែលធ្វើការនៅពេលយប់ចន្លោះពីម៉ោង ២២ ដល់ម៉ោង ៥ ព្រឹក ទោះបីធ្វើការដោយផ្លាស់ប្តូរវេនគ្នាក្តី ទោះបីធ្វើការជាអចិន្ត្រៃយ៍ក្តី កម្មករ និយោជិត ទាំងនោះត្រូវបានប្រាក់ឈ្នួលស្មើ និងពីរដង នៃប្រាក់ឈ្នួលធ្វើការពេលថ្ងៃធម្មតា ដូចគ្នា និងករណីធ្វើការបន្ថែមម៉ោងនៅពេលយប់ដែរ ។

ឧទាហរណ៍: សហគ្រាសមួយមានកម្មករ ១៦ នាក់ ។ កម្មករទាំង ១៦ នាក់នេះ ចែកជាពីរផ្នែក គឺមួយផ្នែកមានកម្មករ ១២ នាក់ ដែលចែកជា ៣ វេនការងារ ក្នុងមួយវេនមានគ្នា ៤ នាក់ ។ កម្មករផ្នែកទី ១ នេះផ្លាស់ប្តូរវេនគ្នាធ្វើការជូនថ្ងៃជូនយប់ ។ ឯកម្មករមួយផ្នែកទៀតមានគ្នា ៤ នាក់ ចែកជាពីរក្រុម មួយក្រុមមានគ្នា ២ នាក់ ធ្វើការជាអចិន្ត្រៃយ៍ ៨ ម៉ោង នៅពេលថ្ងៃ ហើយមួយក្រុមទៀតមានគ្នា ២ នាក់ដែរតែធ្វើការជាអចិន្ត្រៃយ៍នៅពេលយប់ ។ ចំពោះកម្មករ ផ្នែកទី ១ និងកម្មករ ផ្នែកទី ២ ខាងលើ កម្មករណាធ្វើការពេលយប់ដែលមានថិរវេលាចន្លោះពីម៉ោង ២២ ដល់ម៉ោង ៥ ព្រឹក គឺកម្មករនោះត្រូវបានប្រាក់ឈ្នួលស្មើ និងពីរដងនៃប្រាក់ឈ្នួលធ្វើការពេលថ្ងៃធម្មតា សំរាប់ថិរវេលា នៃការងារពេលយប់នោះ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ទាំងអស់ពិតជាយកចិត្តទុកដាក់អនុវត្តតាមត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ជាមិនខាន ។ ការប្រព្រឹត្តល្មើស និងការកំណត់ខាងលើ នឹងត្រូវទទួលទោសដូចមានចែងក្នុងច្បាប់ស្តីពីការងារ ។/

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។/.



អ៊ិត សំហេង

ចម្លងជូន:

-ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍
  "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
  ខេត្ត-ក្រុង "ដើម្បីអនុវត្ត"
-កាលប្បវត្តិ-ឯកសារ